គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

ភ្នំពេញ, ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលបឋមនៃការសង្កេតការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ ២០១២

នៅក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០១២នេះ ខុមហ្វ្រែលបាន និងកំពុងធ្វើសកម្មភាពសង្កេតពីបរិយាកាសសន្តិសុខ និងសិទ្ធិនយោបាយដោយធ្វើការសង្កេត និងអប់រំអ្នកបោះឆ្នោតពីដំណើរការចុះឈ្មោះបោះឆ្នោត និងពិនិត្យបញ្ជីបោះឆ្នោត ការសង្កេតស្រាវជ្រាវការចុះឈ្មោះបោះឆ្នោត និងសវនកម្មបញ្ជីបោះឆ្នោតឆ្នាំ ២០១២ ដោយសកម្មភាពទាំងនេះចាប់ផ្តើមតាំងពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១២។

ដូចការពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១១កន្លងទៅ ក្នុងពេលនេះមានភ្លៀង និងទឹកជំនន់នៅតាមបណ្តាខេត្តមួយចំនួនដូចជាៈ ខេត្តឧត្តរមានជ័យ ព្រះវិហារ បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង សៀមរាប កំពង់ធំ កំពង់ស្ពឺ តាកែវ កណ្តាល ព្រៃវែង ស្វាយរៀង និងខេត្តកំពត។ ស្ថានភាពនេះបានបង្កឲ្យប្រជាពលរដ្ឋ និងមន្ត្រីទទួលបន្ទុកការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតជួបការលំបាក។

មានការប្រឹងប្រែងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្រុមប្រឹក្សាឃុំ/សង្កាត់ និងស្មៀនមួយចំនួនធំដែលបានបំពេញតួនាទីក្នុងការចុះឈ្មោះបោះឆ្នោត។ មកដល់ត្រឹមថ្ងៃទី ២១កញ្ញា បានចុះឈ្មោះថ្មីរហូតដល់ប្រមាណ ៤០៤,៧៣៨នាក់ ស្មើនឹង ៦៥% នៃចំនួនអ្នកចុះឈ្មោះថ្មីប៉ាន់ស្មានសរុបចំនួន៦១៩,៦៣០នាក់។ ជាមួយគ្នានេះដែរបានកែតម្រូវឈ្មោះចំនួន ៣៨,៥២០នាក់ និងលុបឈ្មោះចំនួន ១៤០,៤៤៤នាក់ (លទ្ធផលបណ្តោះអាសន្ននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២ ពីថ្ងៃទី០១ ដល់ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ របស់ គ.ជ.ប)។ គួរបញ្ជាក់ថាក្នុងឆ្នាំ២០១១ គិតត្រឹមថ្ងៃទី២០ មន្ត្រីចុះឈ្មោះអ្នកបោះឆ្នោតថ្មីបានចំនួន ៣៧៥,០០០នាក់ ស្មើនឹង៧៨% នៃតួរលេខប៉ាន់ស្មានអ្នកដែលត្រូវចុះឈ្មោះថ្មីនាឆ្នាំនោះ បានច្រើនជាង ១៣% បើធៀបនឹងឆ្នាំ២០១២នេះ។

យ៉ាងណាមិញ ចំពោះបញ្ហាឈ្មោះស្ទួន ខុមហ្វ្រែលយល់ឃើញថាចំនួនឈ្មោះស្ទួនអាចមានច្រើនជាងចំនួនដែល គ.ជ.ប បានលើកឡើងដែលមានត្រឹមតែប្រមាណ ៥៤,៦០៤នាក់ (០,៥% នៃចំនួនអ្នកបានចុះឈ្មោះបោះឆ្នោត)។ ព្រោះបន្ទាប់ពីការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី ៣ រួចមក ខុមហ្វ្រែលបានសាកល្បងអង្កេតលើបញ្ជីឈ្មោះបោះឆ្នោតនៅសង្កាត់បឹងទំពុន នៅរាជធានីភ្នំពេញ ដោយរកឃើញមានឈ្មោះស្ទួនប្រមាណ ៣% (១២៧នាក់ស្មើនឹងឈ្មោះស្ទួន ២៥៦ ក្នុងចំណោម ៤១៧៨នាក់។ ជាលើកទី១ គ.ជ.ប បានរៀបចំប្រព័ន្ធកុំព្យូទ័រ ដែលស្មៀនអាចផ្ទៀងផ្ទាត់ឈ្មោះ (អ្នកសុំចុះឈ្មោះថ្មី) ដើម្បីបន្ថយឈ្មោះស្ទួន។ ចំណែកចំនួនអ្នកចុះឈ្មោះក្នុងបញ្ជី២០១១មាន ៩,២០៣,៤៩៣នាក់ ដែលបន្ថែមជាមួយអ្នកត្រូវចុះឈ្មោះថ្មី ៦១៩,៦៣០នាក់ និងដកចំនួនដែលត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតមានចំនួន ១៤១,៤៦៧នាក់ សំរាប់បញ្ជីឆ្នាំ ២០១២ ខុមហ្វ្រែលសង្កេតឃើញថាមានចំនួនច្រើនជាងចំនួនអ្នកមានសិទ្ធិបោះឆ្នោតសរុបសម្រាប់ឆ្នាំ ២០១២ ។ ដែលបញ្ហានេះអាចទាក់ទងទៅនឹងបរិមាណអ្នកចុះឈ្មោះថ្មី

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**

**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

ឬអ្នកដែលនឹងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត (ឈ្មោះស្ទួន) ឬបញ្ហាក្នុងការប៉ាន់ប្រមាណអ្នកមានសិទ្ធិបោះឆ្នោតសរុបសម្រាប់ឆ្នាំ ២០១២ ។

យោងតាមសេចក្តីប្រកាសរបស់ គ.ជ.ប ចុះថ្ងៃទី១១ ខែកញ្ញា បានឲ្យដឹងថាក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២នេះមានតំណាងគណបក្សនយោបាយចំនួន ៣,៣៩៩នាក់ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិសរុបចំនួន ២៥៩នាក់ បានចូលរួមសង្កេតការណ៍។ ប៉ុន្តែគណបក្សប្រឆាំងសំខាន់ៗរួមមាន គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានបដិសេធក្នុងការបញ្ជូនភ្នាក់ងាររបស់ខ្លួនទៅចូលរួមសង្កេតការណ៍ក្នុងដំណើរការនេះ ដោយអះអាងថានីតិវិធីនៃការចុះឈ្មោះ ការលុបឈ្មោះអ្នកបោះឆ្នោតអត់មានការផ្លាស់ប្តូរ ដែលវាបានបង្កការលំបាក និងមានភាពស្មុគស្មាញដល់ប្រជាពលរដ្ឋ។ ទន្ទឹមគ្នានេះមន្ត្រីប្រតិបត្តិការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ភាគច្រើនគឺមកពីគណបក្សប្រជាជនកម្ពុជា។ ដូច្នេះគណបក្សទាំងពីរដែលមានតំណាងជាប់ឆ្នោតនៅថ្នាក់ឃុំ/សង្កាត់រហូតដល់ ២,៩៥៥នាក់ គួរមានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យការអនុវត្តន៍ការងារនេះ ដើម្បីធានាថាមន្ត្រីបន្ទុកទាំងនោះអនុវត្តត្រឹមត្រូវតាមច្បាប់ និងនីតិវិធីបោះឆ្នោត។ ជាក់ស្តែងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់មកពីគណបក្សប្រឆាំង ត្រូវបានហាមឃាត់មិនឲ្យលូកដៃចូលក្នុងដំណើរធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោតនេះទេ ព្រោះសមាជិកក្រុមប្រឹក្សាទាំងនោះមិនបានចុះឈ្មោះជាអ្នកសង្កេតការណ៍ ហើយពុំត្រូវបានចាត់តាំងពីប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ ឲ្យជួយពិនិត្យមើល កិច្ចការស្មៀន។ ស្ទើរតែទាំងអស់នៅក្នុងចំណោម ២៥០ ឃុំ/សង្កាត់ ដែលខុមហ្វ្រែលដាក់ពង្រាយអ្នកសង្កេតការណ៍រកឃើញថា គឺមានតែគណបក្សប្រជាជនកម្ពុជាទេ ដែលមេឃុំ/ចៅសង្កាត់ និងក្រុមប្រឹក្សាបានរៀបចំការចុះឈ្មោះបោះឆ្នោត ហើយក៏បានដាក់ភ្នាក់ងារសង្កេតការណ៍របស់ខ្លួន។

នៅក្នុងរបាយការណ៍បឋមគិតត្រឹមថ្ងៃទី២១ ខែកញ្ញា ខុមហ្វ្រែលសង្កេតទៅលើប្រតិបត្តិការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឃើញថាមានភាពមិនប្រក្រតី នៅឃុំ/សង្កាត់មួយចំនួនទាក់ទងនឹងការមិនគោរពនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត ជាពិសេសនៅដំណាក់កាលចាប់ផ្តើមដូចជាការមិនគោរពម៉ោងធ្វើការ ការមិនបិទបញ្ជីបោះឆ្នោតចុងក្រោយ (បញ្ជីឆ្នាំ២០១១) ការចុះឈ្មោះបោះឆ្នោតដោយមិនមានវត្តមានសាមីខ្លួន...។ល។ ដែលអាចធ្វើឲ្យប៉ះពាល់ដល់សិទ្ធិចូលរួមរបស់ប្រជាពលរដ្ឋមួយចំនួនណានោះ។

***<u>ការសង្កេតការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត៖</u>***

ក្នុងចំណោមឃុំ/សង្កាត់ទាំង២៥០ដែលខុមហ្វ្រែលសង្កេត ខុមហ្វ្រែលមានឃើញភាពមិនប្រក្រតីមួយចំនួនដូចខាងក្រោម៖

**ស្មៀនមិនគោរពម៉ោងធ្វើការ ឬយឺតយ៉ាវក្នុងការបើក/បិទការិយាល័យចំនួន៨ឃុំ/សង្កាត់** ដូចជានៅសង្កាត់ប៉ៃលិន សង្កាត់ទួលល្វា និងសង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន ឃុំឧកញ៉ាអុង និងនៅឃុំព្រែកក្មេង ស្រុកល្វាឯម ខេត្តកណ្តាល សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ឃុំល្វា និងឃុំរឿង ស្រុកពួក ខេត្តសៀមរាប។ គួរបញ្ជាក់ថានៅសង្កាត់ប៉ៃលិនមានករណីបើក និងបិទការិយាល័យមិនតាមការកំណត់ញឹកញាប់ជាងគេ។ ករណីជាក់ស្តែងមួយនៃករណីខាងលើគឺនៅក្នុងឃុំព្រែកក្មេង ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ មានការប្រជុំថ្នាក់ឃុំរបស់គណបក្សប្រជាជនកម្ពុជា។ នៅក្នុងកិច្ចប្រជុំនេះមានការចូលរួមពីមេឃុំ ជំទប់ទីមួយ សមាជិកក្រុមប្រឹក្សារបស់គណបក្សប្រជាជនកម្ពុជាចំនួន ២នាក់ និងស្មៀនឃុំ។ ការសង្កេតឃើញថានៅចន្លោះពីម៉ោង ៩:០០ ដល់ ១០:៥៥ នាទីព្រឹកការិយាល័យចុះឈ្មោះនៅសាលាឃុំព្រែកក្មេងនេះ គឺមិនមានមន្ត្រីនៅប្រចាំការដើម្បីដំណើរពិនិត្យឈ្មោះ និងចុះ

ឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋទេ ដែលក្នុងចន្លោះពេលនោះសង្កេតឃើញមានប្រជាពលរដ្ឋចំនួន ៨នាក់បានមកចុះឈ្មោះបោះឆ្នោត។ ដោយរង់ចាំមន្ត្រីចុះឈ្មោះយូរពេកពួកគាត់បានត្រលប់ទៅផ្ទះវិញអស់ចំនួន៥នាក់ ហើយនៅសល់តែ ៣នាក់ នៅរងចាំមន្ត្រីចុះឈ្មោះ។ ដល់ម៉ោងប្រមាណជិត ១១ ព្រឹក ទើបឃើញមន្ត្រីចុះត្រឡប់មកវិញ និងបានដំណើរការចុះឈ្មោះជូនប្រជាពលរដ្ឋ។

**ករណីបាត់ឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតចុងក្រោយ** ចំនួន ២សង្កាត់គឺនៅសង្កាត់ទឹកល្អក់១ និងសង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**ការខកខាន ឬយឺតយ៉ាវបិទបញ្ជីបោះឆ្នោតចុងក្រោយឆ្នាំ២០១១** ចំនួន៤ករណីដែលរួមមាននៅសង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន ឃុំមួយចំនួននៃស្រុងកោះអណ្តែត និងឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ។

**ករណីបិទការិយាល័យពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោត ១ករណី** គឺនៅឃុំកោះខ្ញែ ស្រុកសំបូរ ខេត្តក្រចេះ កាលពីព្រឹកថ្ងៃទី១៩ ខែកញ្ញា ស្មៀនឃុំបានចុះធ្វើតារាងអភិវឌ្ឍន៍ភូមិ ដោយអាក់ខានក្នុងការបើកការិយាល័យពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោតចំនួន១ថ្ងៃ។ នៅក្នុងថ្ងៃនោះដែរមានប្រជាពលរដ្ឋចំនួន ១០នាក់ ទៅចុះឈ្មោះបោះឆ្នោត ប៉ុន្តែបានមិនចុះឈ្មោះទេព្រោះការិយាល័យបានបិទទ្វា ហើយប្រជាពលរដ្ឋទាំងនោះបានត្រឡប់ទៅវិញ។

**ករណីចុះឈ្មោះអ្នកបោះឆ្នោតដោយមិនមានវត្តមានសាមីខ្លួនចំនួន ២ករណី** គឺនៅឃុំមោងឫស្សី ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ គួរបញ្ជាក់ថាកាលពីថ្ងៃទី១៣ ខែកញ្ញា មន្ត្រីបានទៅបើការិយាល័យពិនិត្យឈ្មោះ និងចុះឈ្មោះជូនប្រជាពលរដ្ឋនៅក្នុងភូមិប៉ែន។ ការសង្កេតឃើញថាមានប្រជាពលរដ្ឋ២នាក់ បានមកចុះឈ្មោះបោះឆ្នោតថ្មី ហើយស្របពេលនោះប្រជាពលរដ្ឋទាំងពីរនោះបានយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ប្រជាពលរដ្ឋផ្សេងទៀតម្នាក់មួយៗ ដើម្បីស្នើសុំឲ្យមន្ត្រីឲ្យចុះឈ្មោះអ្នកទាំងនោះ។ ករណីនេះជំនួយការស្មៀនក៏បានចុះឈ្មោះឲ្យប្រជាពលរដ្ឋទាំងពីរនោះដោយមិនមានវត្តមានសាមីខ្លួន។

ការសង្កេតក៏បានរកឃើញផងដែរថាយុវជនមួយចំនួនបានជួយក្នុងការលំបាកក្នុងការបំពេញលក្ខខណ្ឌដើម្បីបានចុះឈ្មោះបោះឆ្នោត ក៏ព្រោះតែពួកគេមិនមានឯកសារបញ្ជាក់អត្តសញ្ញាណ និងខ្វះលក្ខខណ្ឌទីលំនៅពីព្រោះបានចំណាកស្រុកដើម្បីធ្វើការងារ និងការសិក្សាជាដើម។

ករណីមួយដោយឡែកនៅនៅឃុំម៉ាលិក ស្រុកអណ្តូងមាស ខេត្តរតនគីរី កាលពីថ្ងៃទី០២-០៣ ខែកញ្ញា ឆ្នាំ២០១២ សង្កេតឃើញភាពមិនប្រក្រតីមួយគឺមន្ត្រីចុះឈ្មោះ (ស្មៀនឃុំ) បានយកលុយពីប្រជាពលរដ្ឋដែលទៅចុះឈ្មោះបោះឆ្នោតថ្មីប្រមាណជាង១០នាក់ ចន្លោះពី ២០០០រៀល ទៅ១០០០០រៀល (ទៅតាមលទ្ធភាពរបស់ប្រជាពលរដ្ឋ)។ បន្ទាប់ពីសង្កេតឃើញមានភាពមិនប្រក្រតីនេះ អ្នកសង្កេតការណ៍ខុមហ្វ្រែលដែលប្រចាំនៅទីនោះបានរាយការណ៍ទៅសមាជិកក្រុមប្រឹក្សាឃុំប្រចាំការ ដើម្បីសុំអន្តរាគមន៍បញ្ឈប់ករណីនេះ ព្រោះវាថាខុសពីច្បាប់ បទបញ្ជា និងនីតិវិធីបោះឆ្នោតរបស់ គ.ជ.ប។ ដំបូងមានការពិភាក្សា និងទាញរកហេតុផលរៀងៗខ្លួន ប៉ុន្តែក្រោយមកក្រុមប្រឹក្សាឃុំបានធ្វើការអន្តរាគមន៍ទៅស្មៀនឲ្យឈប់យកលុយពីប្រជាពលរដ្ឋដែលមកចុះឈ្មោះបោះឆ្នោត និងបានសំរេចសងលុយទៅប្រជាពលរដ្ឋទាំងនោះវិញ។ គួរបញ្ជាក់ថាបើតាមការរាយការណ៍ចុងក្រោមបានឲ្យដឹងថាមន្ត្រីចុះឈ្មោះ និងក្រុមប្រឹក្សាឃុំបានអះអាងថាករណីយកលុយនេះគឺសំរាប់ធ្វើអត្តសញ្ញាណប័នសញ្ញាតិខ្មែរទៅវិញ។

រីឯនៅសង្កាត់បយ៉ាខា ក្រុងប៉ៃលិន ខេត្តប៉ៃលិន មានករណីមេភូមិបរហ៊ុយត្បូង និងភ្នាក់ងារសង្កេតការណ៍របស់គណបក្សប្រជាជនកម្ពុជាម្នាក់ បានអង្គុយចាំកត់លេខអត្តសញ្ញាណប័ណ្ណ និងឈ្មោះប្រជាពលរដ្ឋដែលបានមកពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ ដោយឡែកចំពោះអ្នកដែលគ្មានអត្តសញ្ញាណប័ណវិញ សង្កេតឃើញមេភូមិ និងភ្នាក់ងារគណបក្សនោះបានធ្វើការផ្ទៀងផ្ទាត់លិខិតបញ្ជាក់អត្តសញ្ញាណផ្សេងៗរបស់អ្នកបោះឆ្នោតជាមួយនឹងបញ្ជីបោះឈ្មោះ។ គួរបញ្ជាក់ថាករណីនេះគឺបានកើតឡើងតាំងពីថ្ងៃទី០១ មកដល់ថ្ងៃទី១១ ខែកញ្ញានេះ ដោយនៅចាំកត់ឈ្មោះជារៀងរាល់ថ្ងៃ។ ទោះជាយ៉ាងណាការសង្កេតមិនបានរកឃើញពីមូលហេតុច្បាស់លាស់ថាកត់ និងផ្ទៀងផ្ទាត់ឈ្មោះដើម្បីអ្វីនោះទេ។ ទន្ទឹមនឹងនេះក៏មានករណីនៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតនៅសង្កាត់បយ៉ាខានេះហាក់មិនបានគោរពតាមនីតិវិធីរបស់ គ.ជ.ប ពោលគឺស្មៀនជាអ្នកចេញលិខិតនេះឲ្យប្រជាពលរដ្ឋ ដោយចៅសង្កាត់បានចុះហត្ថលេខាទុកជាមុន ហើយនៅពេលមានការស្នើសុំពីប្រជាពលរដ្ឋ ស្មៀនគ្រាន់តែបំពេញបែបបទ និងបោះត្រាជាការស្រេច។ ករណីដូចគ្នានេះក៏បានកើតឡើងនៅសង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិននេះផងដែរ។

***<u>ការអប់រំ និងការផ្តល់ព័ត៌មានអំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត៖</u>***

ក្នុងដំណើរពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១កន្លងមក ខុមហ្វ្រែលសង្កេតឃើញថាការអប់រំ និងការផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតដែលចាត់ចែងដោយគណបក្សនយោបាយត្រូវបានបង្កឧបសគ្គដោយអាជ្ញាធរមូលដ្ឋានមួយចំនួន ដែលមិនទទួលខុសត្រូវសម្របសម្រួលដល់ការចូលរួមរបស់គណបក្សនយោបាយទាំងនេះ។ សម្រាប់ដំណើរការក្នុងឆ្នាំ២០១២ ក៏បន្តមានបញ្ហាដដែលនេះដែរ ជាក់ស្តែងកាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១២ នៅឃុំសៀងឃ្វាង ស្រុកកំចាយមា ខេត្តព្រៃវែង មានករណីរារាំងពីមេភូមិមកពីគណបក្សប្រជាជនកម្ពុជា មិនឲ្យសកម្មជនរបស់គណបក្សសិទ្ធមនុស្ស ធ្វើការអំពាវនាវឲ្យប្រជាពលរដ្ឋទៅពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដោយសំអាងថាការងារនេះជាភារៈកិច្ចរបស់អាជ្ញាធរភូមិ/ឃុំ។

ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១១កន្លងមក ការសង្កេតក៏ឃើញថាគណបក្សនយោបាយនានាបង្ហាញពីការលំបាករបស់ខ្លួននៅក្នុងការងារអប់រំផ្សព្វផ្សាយនេះ ដែលបង្កឡើងដោយអាជ្ញាធរមូលដ្ឋាន។ គួរបញ្ជាក់ថានាពេលនោះ គ.ជ.ប បែរជាដោះដៃចេញមិនទទួលខុសត្រូវ ហើយមិនព្រមជួយសម្រួលជាមួយស្ថាប័នពាក់ព័ន្ធទាំងនោះ តែបែរជាទុកឲ្យអ្នកអប់រំទាំងនោះ ដោះស្រាយដោយខ្លួនឯង ឬពេលខ្លះបន្ទោសឬចាត់ទុកថា សកម្មភាពនោះខុសច្បាប់ ឬខូចសណ្តាប់ធ្នាប់ទៅវិញ។ ច្បាប់បោះឆ្នោតបានកំណត់ថា គ.ជ.ប ជាអ្នកទទួលខុសត្រូវធ្វើផែនការរៀបចំ និងចាត់ចែងការបោះឆ្នោតក្នុងទូទាំងប្រទេស ហើយ គ.ជ.ប មានសិទ្ធិពេញលេញក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួនដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ហើយ គ.ជ.ប ក៏មានសិទ្ធិក្នុងការស្នើសុំកិច្ចសហការពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារផ្សេងៗទៀតក្នុងសម័យកាលបោះឆ្នោត ការឃោសនាបោះឆ្នោតផងដែរ។ ដូចនេះគ.ជ.ប ត្រូវទទួលខុសត្រូវ និងសម្របសម្រួលការងារចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះរួមទាំងគាំទ្រ លើកទឹកចិត្តមិនរើសអើងដល់សកម្មភាពអប់រំ/ផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ រួមទាំងគណបក្សនយោបាយ។

សម្រាប់ឆ្នាំ២០១២នេះ គ.ជ.ប បានបំពេញតួនាទីក្នុងការផ្សព្វផ្សាយគួរឲ្យកត់សម្គាល់ជាងឆ្នាំកន្លងមក និងបានបង្កើតមជ្ឈមណ្ឌលប្រហែល ៦១៨កន្លែង ដើម្បីជួយស្វែងរកឈ្មោះអ្នកបោះឆ្នោត ក្នុងបញ្ជីបោះឆ្នោតតាមប្រព័ន្ធអ៊ីនធឺណេត តាមគេហទំព័រ voterlist.org.kh ដើម្បីផ្តល់ព័ត៌មានជូនអ្នកបោះឆ្នោត ដែលប្រតិបត្តិដោយលេខាធិការដ្ឋានរាជធានី-ខេត្តរៀបចំការបោះឆ្នោត។

ជាមួយគ្នានេះសង្គមស៊ីវិលមួយចំនួនក៏បានចូលរួមចំណែកក្នុងការអប់ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋផងដែរ។ ជាមួយគ្នានេះការអប់រំ និងផ្សព្វផ្សាយត្រូវបានពិនិត្យឃើញថាអាជ្ញាធរមូលដ្ឋានបានដើរតួនាទីយ៉ាងសំខាន់ ព្រោះថាច្បាប់បោះឆ្នោតបានប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ/សង្កាត់បំពេញការងារចុះឈ្មោះ និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ហើយស្របពេលដែលខុមហ្វ្រែលបានសិក្សាស្រាវជ្រាវឃើញថា ៨០.៦% នៃអ្នកបោះឆ្នោតបានទទួលព័ត៌មានពីដំណើរការចុះឈ្មោះពីមេភូមិ (លទ្ធផលស្រាវជ្រាវអំពីការចុះឈ្មោះ និងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១១របស់ខុមហ្វ្រែល) ប៉ុន្តែការសង្កេតឃើញថានៅតែមានករណីរើសអើងនិន្នាការគណបក្សនយោបាយ និងការអប់រំផ្សព្វផ្សាយនៅមានកម្រិតពីសំណាក់អាជ្ញាធរមូលដ្ឋានមួយចំនួនដូចជានៅឃុំផ្ទះរ៉ុង និងឃុំលាជ ក្នុងស្រុកភ្នំក្រវ៉ាន ខេត្តពោធិ៍សាត់ និងឃុំអំពៅព្រៃ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ជាដើម។

ជាសរុបប្រតិបត្តិការនៃការចាត់ចែងចុះឈ្មោះបោះឆ្នោតដោយ គ.ជ.ប និងក្រុមប្រឹក្សាឃុំ/សង្កាត់ និងស្មៀនឃុំ/សង្កាត់ អាចដំណើរការសម្រេចលទ្ធផលតាមផែនការ និងស្ថិតិដែល គ.ជ.ប បានគ្រោងទុក ប៉ុន្តែលទ្ធផលនៃគុណភាពព្រមទាំងបរិមាណអ្នកចុះឈ្មោះបោះឆ្នោតបានច្រើននេះមិនទាន់ធានាថា អ្នកបោះឆ្នោតពិតជាមានឈ្មោះត្រឹមត្រូវដែលពួកគេអាចបោះឆ្នោតបាននៅថ្ងៃទី ២៨ កក្កដា ២០១៣ ខាងមុខទេ ព្រោះថាបើទោះជា គ.ជ.ប បានធ្វើលើសការប៉ាន់ស្មានរបស់ខ្លួន ក៏ខុមហ្វ្រែលនៅរកឃើញថានៅមានអ្នកមានសិទ្ធិបោះឆ្នោតមួយចំនួនមិនបានទៅចុះឈ្មោះបោះឆ្នោត។

***បណ្តឹង***

ក្នុងកំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ខុមហ្វ្រែលបានសង្កេតឃើញថាពុំមានបណ្តឹងណាមួយដែលបានប្តឹងជុំវិញការចុះឈ្មោះ និងពិនិត្យឈ្មោះបោះឆ្នោតនេះទេ ។ នេះអាចបញ្ជាក់បានថាដោយសារតែពុំមានការចូលរួមសង្កេតការណ៍របស់គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ពីព្រោះថាបើធៀបទៅនឹងការចុះឈ្មោះ និងពិនិត្យឈ្មោះបោះឆ្នោតឆ្នាំ ២០១១ បណ្តឹងភាគច្រើនត្រូវបានប្តឹងដោយគណបក្សនយោបាយដូចជាគណបក្សសមរង្ស៊ីជាដើម ។ ប្រជាពលរដ្ឋ មិនបានលើកទឹកចិត្តក្នុងការធ្វើបណ្តឹងដោយខ្លួនឯង ដោយសារតែប្រជាពលរដ្ឋភាគច្រើនមិនបានដឹងពីដំណើរការនៃការដាក់ពាក្យបណ្តឹង ។

***អានុសាសន៍***

ដើម្បីបើកទូលាយ និងអនុញ្ញាតឲ្យភាគីដែលពាក់ព័ន្ធបានចូលរួមត្រួតពិនិត្យដ៏មានប្រសិទ្ធិភាពមួយក្នុងការកសាងនិងបង្កើតនូវបញ្ជីឈ្មោះបោះឆ្នោតប្រចាំឆ្នាំមួយដែលមានសុក្រឹតភាព និងគុណភាពដែលអាចជឿទុកចិត្តបាន ខុមហ្វ្រែលសូមផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោម៖

១. ស្នើសុំអនុញ្ញាតធ្វើការថតចម្លងនូវបញ្ជីឈ្មោះដែលមេឃុំ/ចៅសង្កាត់បានចេញនូវលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោតឲ្យបានចំនួនពីរដងគឺៈ

-លើកទីមួយគឺក្រោយពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និង

-លើកទីពីរគឺមួយខែ (៣០ថ្ងៃ) មុនថ្ងៃបោះឆ្នោត។

ម៉្យាងទៀតត្រូវមានការបើកចំហគល់បញ្ជី ដែលអាចឲ្យមានការត្រួតពិនិត្យផ្ទៀងផ្ទាត់ជាមួយបញ្ជីហើយទុកពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ឈ្មោះដែលត្រូវបានលុបដោយគ.ជ.ប។

២. ស្នើសុំអនុញ្ញាតធ្វើការថតចម្លងនូវបញ្ជីឈ្មោះដែលត្រូវបានលុបដោយ គ.ជ.ប ដើម្បីឲ្យអង្គការសង្កេតការណ៍បោះឆ្នោត និងគណបក្សនយោបាយ បានដឹងអំពីឈ្មោះ និងចំនួនអ្នកបោះឆ្នោតដែលត្រូវបានលុបក្នុងកំឡុងពេលចុះឈ្មោះបោះឆ្នោតនេះ។

៣. ស្នើសុំអនុញ្ញាតឲ្យតំណាងគណបក្សនយោបាយ និងអង្គការសង្កេតការណ៍បោះឆ្នោតធ្វើការថតចម្លងនូវបញ្ជីឈ្មោះ ដែលស្មៀនឃុំបានចុះឈ្មោះ រួចហើយនោះជារៀងរាល់ចុងសប្តាហ៍។

៤. ស្នើសុំឲ្យគ.ជ.ប ត្រូវតែពង្រឹងនូវយន្តការសម្រាប់ធ្វើអន្តរាគមន៍ចំពោះអ្នកដែលត្រូវគេបដិសេធមិនចុះឈ្មោះបោះឆ្នោតដោយសារខ្វះឯកសារបញ្ជាក់ទីលំនៅ។

**យន្តការនេះរួមមាន លេខទូរសព្ទ័ទាក់ទង និងក្រុមមន្ត្រីច្បាស់លាស់។**

៥. ស្នើសុំឲ្យគ.ជ.ប ខិតខំផ្សព្វផ្សាយបន្ថែមទៀតទាក់ទងទៅនឹងការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោតប្រចាំឆ្នាំថែមទៀត។

៦. ស្នើសុំឲ្យគ.ជ.ប និងក្រសួងមហាផ្ទៃត្រូវធ្វើសេចក្តីណែនាំទៅអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងបើកទូលាយឲ្យគណបក្សនយោបាយ និងអង្គការសង្គមស៊ីវិល្ញចូលរួមធ្វើការផ្សព្វផ្សាយការអប់រំ និងព័ត៌មានស្តីពីការបោះឆ្នោតជាពិសេសការចុះឈ្មោះ និង ពិនិត្យបញ្ជីឈ្មោះបោះឆ្នោត។

***<u>សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:</u>***

កញ្ញា គង់ រ៉ាវីន, អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល, ០១២ ៦៥៤ ៩៥០, អ៊ីម៉ែល: ravine@comfrel.org

លោក ស្រី សុភ័ក្រ, មន្ត្រីជាន់ខ្ពស់ផ្នែកព័ត៌មាន និងច្បាប់, ០១២ ៩៩៨ ៣៦៤, អ៊ីម៉ែល: sreysopheak@comfrel.org

*<u>**បេសកម្ម**</u> ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។*